**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ :......០២៤...../២៥...........ក.ប/ស.ជ.៣.អ.ច.ក

# សេចក្តីជូនដំណឹង

## ស្តីពី

## វគ្គបណ្តុះបណ្តាលពិសេសសម្រាប់បុគ្គលទទួលបន្ទុកផ្នែករដ្ឋបាលនិងធនធានមនុស្ស នៃសហគ្រាស គ្រឹះស្ថាន សម្រាប់ឆ្នាំ២០២៥

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងប្រកាសលេខ ២៥៩/២៤ ក.ប/ប្រ.ក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការកំណត់គុណវុឌ្ឍិបុគ្គលទទួលបន្ទុកផ្នែករដ្ឋបាល និងធនធានមនុស្ស នៃសហគ្រាស គ្រឹះស្ថាន ក៏ដូចជាចូលរួមលើកកម្ពស់ផលិតភាពការងារនៅតាមសហគ្រាស គ្រឹះស្ថានទាំងអស់ សំដៅធានាឱ្យបាននូវសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ វិទ្យាស្ថានជាតិការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងផ្តល់វគ្គបណ្តុះបណ្តាលពិសេសសម្រាប់បុគ្គលទទួលបន្ទុកផ្នែករដ្ឋបាលនិងធនធានមនុស្សនៃសហគ្រាស គ្រឹះស្ថាន ដែលមានរយៈពេល ៣០ (សាមសិប) ម៉ោងដោយឥតគិតថ្លៃសម្រាប់ឆ្នាំ២០២៥ ជូនចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះឈ្មោះប្រើប្រាស់សេវាសាធារណៈក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារតាមរយៈគេហទំព័រ https://lacms.mlvt.gov.kh។

ម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវចាត់បញ្ជូនកម្មករនិយោជិតចំនួន ១ (មួយ) រូប ប្រចាំសហគ្រាស ឬ ១ (មួយ) រូប ប្រចាំគ្រឹះស្ថានរបស់ខ្លួន ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលខាងលើ ដោយត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១- កំពុងបំពេញតួនាទីជាប្រធានផ្នែករដ្ឋបាល និង/ឬធនធានមនុស្ស នៃសហគ្រាស គ្រឹះស្ថាន។

២- មានបទពិសោធការងារជាប្រធានផ្នែករដ្ឋបាល និង/ឬធនធានមនុស្ស យ៉ាងតិច ៣ (បី) ឆ្នាំជាប់គ្នា។

៣- មានលិខិតបញ្ជាក់ពីនិយោជកដែលជាម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថាន។

បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលខាងលើដោយជោគជ័យ សិក្ខាកាមនឹងទទួលបានវិញ្ញាបនបត្របញ្ជាក់ការចូលរួមសម្រាប់ស្នើសុំលិខិតទទួលស្គាល់គុណវុឌ្ឍិបុគ្គលទទួលបន្ទុកផ្នែករដ្ឋបាល និងធនធានមនុស្ស នៃសហគ្រាស គ្រឹះស្ថាន ដោយឥតគិតថ្លៃ ដែលមានសុពលភាពរយៈពេល ៣ (បី) ឆ្នាំ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៩៣ សហវ.ប្រក.អទច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៥ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្នុងន័យនេះ សូមម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្រោមដែនអនុវត្តនៃច្បាប់ស្តីពីការងារ រៀបចំបញ្ជីឈ្មោះកម្មករនិយោជិតតាមលក្ខខណ្ឌខាងលើជូនមកវិទ្យាស្ថានជាតិការងារ នៃក្រសួងការងារ និងបណ្តុះ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

បណ្ដាលវិជ្ជាជីវៈ និងស្កេនកូដឆ្លើយតបរហ័ស (QR Code) ខាងក្រោម ដើម្បីចុះឈ្មោះចូលរៀនវគ្គបណ្ដុះបណ្ដាល ខាងលើ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ដំណាច់ឆ្នាំ២០២៥។

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ចូលរួមអនុវត្តតាមខ្លឹមសារសេចក្ដីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ សុក្រ ៨រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០២៥

រដ្ឋមន្ត្រី

**ហេង សួរ**

ស្កេនដើម្បីចុះឈ្មោះ